# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1534

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : លុបបំបាត់គ្រឿងញៀនតាមរយៈវត្តអារាមព្រះពុទ្ធសាសនា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/25

កាលបរិច្ឆេទបញ្ចប់គម្រោង 01/01/25

៣. ចំណាយគម្រោងសរុប $320,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងធម្មការនិងសាសនា

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ចូលរួមការលើកកម្ពស់ការយល់ដឹង និងជំរុញតួនាទីព្រះពុទ្ធសាសនានៅក្នុងការចូលរួមអប់រំសីលធម៌, គុណធម៌ និងសុជីវធម៌ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនដល់សិស្ស និស្សិត និងយុវជនទាំងក្នុងនិងក្រៅប្រព័ន្ធអប់រំ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

សហគមន៍ និងសេវាកម្មសង្គម

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ, កណ្ដាល, សៀមរាប, បាត់ដំបង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

កសាងវត្តអារាមក្លាយជាមជ្ឈមណ្ឌលធនធាន បណ្ដុះនូវពុទ្ធិ បញ្ញា ស្មារតី សីលធម៌ និងគុណធម៌ តាមមាគ៌ា ព្រះពុទ្ធ សាសនា សម្រាប់កុមារ យុវជន និងពុទ្ធបរិស័ទទូទៅ ជៀសផុតពីគ្រឿងញៀនគ្រប់ប្រភេទ ក្នុងរាជធានី ភ្នំពេញ និងតាមបណ្ដាខេត្តនានា ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ក្រសួងធម្មការនិងសាសនា បានរៀបចំគម្រោងនេះដោយមានសកម្មភាពអាទិភាពចំនួន០៣ផ្នែក និងយុទ្ធសាស្ត្រ អនុវត្តសំខាន់ៗ មានដូចខាងក្រោម៖

សកម្មភាពអាទិភាពទី១៖ ការកសាងគោលការណ៍ណែនាំ និងលិខិតបទដ្ឋានស្ដីពីវត្តអារាមគ្មានគ្រឿងញៀន៖

យុទ្ធសាស្ត្រអនុវត្តសំខាន់ៗរួមមាន៖

លេខាធិការដ្ឋាន នៃគណៈកម្មការតាក់តែងសេចក្ដីព្រាងច្បាប់ ដែលត្រូវបានបង្កើតដោយក្រសួងធម្មការ និង សាសនា និងដឹកនាំការរៀបចំ "គោលការណ៍ណែនាំថ្នាក់ជាតិស្ដីពីវត្តអារាមគ្មានគ្រឿងញៀន" (National Guideline on Free Drug in Buddhist Monastery) ដោយសហការជាមួយស្ថាប័នរាជរដ្ឋាភិបាលពាក់ ព័ន្ធដូចជា៖ អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង គណៈសង្ឃនាយកទាំង២គណៈ នៃព្រះរាជាណាចក្រកម្ពុជា។

កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនិងក្រុមការងារតាក់តែងគោលការណ៍នឹងត្រូវបានរៀបចំ ដើម្បីស្វែងរកជាតុចូលនិងសម្រេចជាគោលការណ៍ណែនាំ ថ្នាក់ជាតិមួយសម្រេចដោយឯកឧត្ដមបណ្ឌិតរដ្ឋមន្ត្រី ក្នុងទិសដៅជម្រុញតួនាទីព្រះសង្ឃក្នុងកិច្ចការលុបបំបាត់ គ្រឿងញៀន និងទប់ស្កាត់ទីតាំងវត្តអារាមជាកន្លែងប្រើប្រាស់គ្រឿងញៀន ។

សហការជាមួយគណៈសង្ឃនាយកទាំង២គណៈ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយ "គោលការណ៍ណែនាំថ្នាក់ជាតិស្ដីពីវត្តអារាមគ្មានគ្រឿងញៀន" ថ្វាយនិងប្រគេនសម្ដេចព្រះសង្ឃនាយកសម្ដេច ព្រះសង្ឃនាយករង ព្រះមន្ត្រីសង្ឃជាន់ខ្ពស់ ព្រះមេគុណរាជធានី/ខេត្ត ព្រមទាំងមន្ត្រីរាជការស៊ីវិលពាក់ព័ន្ធ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ សិក្ខាសាលានេះមានទិសដៅបង្ហាញអំពីគោលបំណងចម្បងនៃគោលការណ៍ ណែនាំ ដែលរួមចំណែកអនុវត្តផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្ដេជ្ញាចិត្តថា៖ កម្ពុជាជាប្រទេសគ្មានគ្រឿងញៀន និងរក្សាគ្រួសារនិមួយៗ ជាគ្រួសារស្អាតស្អំ គ្មានគ្រឿងញៀន តាមទស្សនវិស័យ "ចូលរួមទាំងអស់គ្នា ដើម្បីជីវិតនិងសហគមន៍គ្មានគ្រឿងញៀន"។ ជាមួយគ្នានេះ សិក្ខាសាលាថ្នាក់ជាតិនឹងជំរុញការរៀបចំផែនការ សម្រាប់គណៈសង្ឃដាក់ឱ្យប្រើប្រាស់ និងអនុវត្តគោលការណ៍ ណែនាំនៅតាមវត្តអារាមទូទាំងប្រទេស។

សកម្មភាពអាទិភាពទី២៖ ការបណ្ដុះបណ្ដាល អប់រំ និងផ្សព្វផ្សាយស្ដីពីការយល់ដឹងផលប៉ះពាល់គ្រឿងញៀន៖

យុទ្ធសាស្ត្រអនុវត្តសំខាន់ៗរួមមាន៖

សហការជាមួយក្រុមការងារបច្ចេកទេស នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីរៀបចំវគ្គបណ្ដុះបណ្ដាល គ្រូបង្គោល (Training of Trainers) ប្រគេនគណៈសង្ឃដែលនឹងត្រូវជ្រើសរើសតំណាងវត្តអារាម ស្ថិតក្នុងគោលដៅរាជធានីភ្នំពេញនិងបណ្ដាខេត្តនានា លើប្រធានបទ ចំណេះដឹង និងវិធីសាស្ត្រសម្របសម្រួល ផ្សព្វផ្សាយការ យល់ដឹងដោយស៊ីជំរៅ ទូលំទូលាយ និងចំគោលដៅស្ដី ពីផលប៉ះពាល់គ្រឿងញៀន វិធានការអនុវត្តនានា។

គំរោងនឹងបន្តគាំទ្រព្រះសង្ឃជាគ្រូបង្គោល ដើម្បីរៀបចំផែនការអនុវត្តសកម្មភាពផ្សព្វផ្សាយ បន្តប្រគេន និងជូនដល់ព្រះសង្ឃ គណៈកម្មការ ពុទ្ធបរិស័ទ និងសិស្ស/និស្សិតស្នាក់នៅក្នុងវត្តអារាម នៃខេត្តគោលដៅ ដោយយផ្ដោតលើខ្លឹមសារទិសស្លោក "បីកុំ មួយរាយការណ៍" គឺ៖ កុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់ករណីបទល្មើសគ្រឿងញៀន។

សហការជាមួយគណៈសង្ឃនាយកទាំងពីរគណៈ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំផែនការ និងប្រកាស អនុវត្តសេក្ដីណែនាំប្រគេនដល់គណៈសង្ឃវត្តអារាមព្រះពុទ្ធសាសនានៅទូទាំងប្រទេស ប្រារព្ធពិធីយុទ្ធនាការ "ថ្ងៃឧបោសថសីល ថ្ងៃគ្មានគ្រឿងញៀន" តាមរយៈការចុះអប់រំផ្ទាល់នៅតាមសាលារៀន សហគមន៍ក្នុងវត្តអារាម និងការទូងស្គរជាសញ្ញាក្រើនរំលឹកដល់ពុទ្ធបរិស័ទនិងមហាជនទូទៅអំពីការ ចូលរួមលុបបំបាត់គ្រឿងញៀន និងការកាត់បន្ថយគ្រឿងស្រវឹង ដែលមានផលប៉ះពាល់ដល់អាយុជីវិត មនុស្ស និងសីលធម៌សង្គម ជាដើម ។

សកម្មភាពអាទិភាពទី៣៖ ការអនុវត្តកិច្ចការរដ្ឋបាល និងកិច្ចសហប្រតិបត្តិការបង្ក្រា និងទប់ស្កាត់គ្រឿងញៀន៖

យុទ្ធសាស្ត្រអនុវត្តសំខាន់ៗរួមមាន៖

សម្របសម្រួលជាមួយគណៈសង្ឃ និងព្រះមន្ត្រីសង្ឃ នៃសាលាគណរាជធានីភ្នំពេញ (១៥១វត្ត) សាលាគណខេត្តសៀមរាបចំនួន២៦១វត្ត បាត់ដំបងចំនួន៣៨៣វត្ត និងកណ្ដាលចំនួន៣៥៩វត្ត សរុបចំនួន ១ ១៥៤វត្ត ដើម្បីរៀបចំផែនការអនុវត្តវិធានការវត្តអារាមគ្មានគ្រឿងញៀន សម្រាប់គ្រប់វត្តអារាមអនុវត្តលើវិធាននានាដូចជា៖ ក្រមសីលធម៌ព្រះសង្ឃនិងគ្រហស្ថកុំពាក់ព័ន្ធ និងចំណាត់ការសម្រាប់គណៈសង្ឃគ្រប់គ្រង និងដឹកនាំវត្តអារាមជាទីតាំងគ្មានគ្រឿងញៀន ។

សហការជាមួយគណៈសង្ឃនាយកទាំង២គណៈ នៃព្រះរាជណាចក្រកម្ពុជា និងព្រះមន្ត្រីសង្ឃរាជធានី ខេត្ត ដើម្បីរៀបចំកម្មវិធីសំណេះសំណាល និងអប់រំផ្លូវចិត្តតាមពុទ្ធមាគ៌ាសម្រាប់ជនរងគ្រោះដែលកំពុងស្នាក់ក្នុងមណ្ឌលអប់រំ បន្សាបព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ ក្រសួងធម្មការនិងសាសនានឹងរៀបចំកម្មវិធីសំណេះសំណាលនៅតាមមណ្ឌលចំនួន០៤ ក្នុងរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តសៀមរាប និងខេត្តបាត់ដំបង។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

វត្តអារាម និងព្រះសង្ឃ មានឥទ្ធិពលដ៏សំខាន់សម្រាប់ការអប់រំ និងបណ្ដុះបណ្ដាលចំណេះដឹងដល់ប្រជាជន ជាពិសេសកុមារ និងយុវជន ដែលជាជនងាយរងគ្រោះដោយបញ្ហាគ្រឿងញៀន ។

វត្តអារាមមួយចំនួនបានក្លាយជាទីតាំងជួញដូរ និងប្រើប្រាស់គ្រឿងញៀន ដែលសមត្ថកិច្ចបានស្រាវជ្រាវ បានរកឃើញ និងបានបង្ក្រាបបទល្មើសគ្រឿងញៀន ។

ផ្អែកលើបញ្ហាប្រឈម ធនធាន សក្ដានុពលវត្តអារាម និងព្រះសង្ឃ ព្រមទាំងតួនាទី ភារកិច្ចរបស់ក្រសួងធម្ម ការ និងសាសនា (អនុក្រឹត្យ.១៥៤អនក្របក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១) គម្រោងនេះ រៀបចំឡើងក្នុងទិសដៅរួមចំណែកអនុវត្តផែនការយុទ្ធនាការប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៩ ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារកិត្តិយស កិត្យានុភាពជាតិ បញ្ចៀសឱ្យបាននូវភាពរងគ្រោះដោយសារ ឧក្រិដ្ឋកម្មគ្រឿងញៀន ។

តាមរយៈផែនការសកម្មភាពអាទិភាព យុទ្ធសាស្ត្រអនុវត្តនឹងសម្រេចបាននូវលទ្ធផល រួមចំណែកក្នុងគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" ។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

រាជរដ្ឋាភិបាល ព្រះសង្ឃ គណៈកម្មការវត្ត កុមារនិងយុវជន។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្ដើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

មិនមានផលប៉ះពាល់បរិស្ថាន និងសង្គមទេ។ គម្រោងនេះ នឹងជួយដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការទប់ស្កាត់គ្រឿងញៀន ធ្វើឱ្យយុវជនមានសុខភាពល្អ ជាកំលាំងពលកម្មសម្រាប់សង្គមជាតិ។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ទាំងបុរស និងស្ត្រីទទួលបានការអប់រំពីព្រះសង្ឃទាំងអស់គ្នា រួមទាំងយុវជនទាំងក្នុង និងក្រៅប្រព័ន្ធអប់រំ**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 ថវិកា | 2023 ដាក់ស្តែង | 2024 ថវិកា | 2025 ប៉ាន់ស្មាន | 2026 ប៉ាន់ស្មាន | 2027 ប៉ាន់ស្មាន | សរុប 2025-2027 | ថវិកាចរន្ត |
|---|---|---|---|---|---|---|---|---|
| ចំណាយប្រតិបត្តិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 110.0 | 110.0 | 100.0 | 320.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 110.0 | 110.0 | 100.0 | 320.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 110.0 | 110.0 | 100.0 | 320.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 110.0 | 110.0 | 100.0 | 320.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: